## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

*********

# កិច្ចព្រមព្រៀង

## រវាង

## រោងចក្រ ប្រ៊ីលលាន អេចខេ ( ខេមបូឌា ) ហ្វេកធើរី ឯ.ក

## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ

នៅថ្ងៃទី.១៣..ខែ..តុលា...ឆ្នាំ២០២២ វេលាម៉ោង០៩.និង.៣០.នាទី នៅក្នុង

**រោងចក្រ ប្រ៊ីលលាន អេចខេ (ខេមបូឌា) ហ្វេកធើរី ឯ.ក**

មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ នឹងតំណាងកម្មករ និយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយករោងចក្របានជូនដំណឹងដល់កម្មករ និយោជិកទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃរោងចក្រដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ហេតុដូចនេះរោងចក្រសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិកចំនួន ...៣៧៦...(ស្រី...២៤៥.នាក់)ក្នុងចំណោម កម្មករ និយោជិកសរុបចំនួន..៣៧៦...(ស្រី..២៤៥...នាក់)។ រយៈពេល.១..ខែ ដោយគិតចាប់ពីថ្ងៃទី.២០..ខែ.តុលា...ឆ្នាំ ២០២២ ដល់ថ្ងៃទី..១៩.ខែ..វិច្ឆិកា...ឆ្នាំ២០២២។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករ និយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឈ្នួល ៥០%នៃប្រាក់ឈ្នួលប្រចាំថ្ងៃ ដោយរក្សាប្រាក់ថ្លៃធ្វើដំណើរ៧ដុល្លានៅដដែល(ចំពោះកម្មករដែលមានបំណាច់ឆ្នាំសូមប្រើចំណាច់ឆ្នាំសិន)៕

ប្រាក់ឧបថមក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងានេះ និងបើកជូនបងប្អូនកម្មករនៅថ្ងៃទី.១០.នៅខែបន្ទាប់។

អង្គប្រជុំបានចប់នៅវេលាម៉ោង..១០..និង០០..នាទី ព្រឹកនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃ..ព្រហស្បតិ៍៣..ខែអស្សុជ.ឆ្នាំខាល ទោលស័ក ពុទ្ធសករាជ ២៥៦៦

រាជធានី ភ្នំពេញ ថ្ងៃទី.១៣..ខែ..តុលា..ឆ្នាំ២០២២

**តំណាងរោងចក្រ**

**ស្នាមមេដៃតំណាងកម្មករ និយោជិក**